អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres extraordinaires au sein des tribunaux cambodgiens

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

ភ្នំពេញ ថ្ងៃទី២៨ ខែមករា ឆ្នាំ២០១១

# សេចក្តីប្រកាសព័ត៌មាន

## ដំណឹងចុងក្រោយ: អង្គជំនុំជម្រះសាលាដំបូងនឹងបើកសវនាការរួមមួយជាសាធារណៈ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១

អង្គជំនុំជម្រះសាលាដំបូងនៃអង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក) បានសម្រេចថា នឹងបើកសវនាការរួមមួយជាសាធារណៈ នៅថ្ងៃទី៣១ ខែមករា ឆ្នាំ២០១១ ដើម្បីសម្រេចសេចក្តីទៅលើពាក្យស្នើសុំផ្ទាល់មាត់ទាក់ទិននឹង៖

- “ពាក្យស្នើសុំបន្ទាន់ឲ្យដោះលែងលោក នួន ជា នៅក្រៅឃុំ”។ ខ្លឹមសារពិស្តារនៃពាក្យសុំនេះមាននៅ: http://www.eccc.gov.kh/english/cabinet/courtDoc/824/E19_1_EN.PDF
- “ពាក្យស្នើសុំរបស់លោក ខៀវ សំផន ដើម្បី នៅក្រៅឃុំ ដោយយោងតាមមាត្រា ៨២(៣) នៃវិធានផ្ទៃក្នុង”។ ខ្លឹមសារ ពិស្តារនៃពាក្យសុំនេះមាននៅ: http://www.eccc.gov.kh/english/cabinet/courtDoc/823/E18_1_EN.PDF
- “ពាក្យស្នើសុំបន្ទាន់ឲ្យដោះលែងលោកស្រី អៀង ធិរិទ្ធ នៅក្រៅឃុំ” ។ ខ្លឹមសារពិស្តារនៃពាក្យសុំនេះមាននៅ: http://www.eccc.gov.kh/english/cabinet/courtDoc/830/E21_EN.PDF

សវនាការនឹងចាប់ផ្តើមនៅម៉ោង ០៩:៣០នាទីព្រឹក។ សហមេធាវីការពារក្តីឲ្យជនត្រូវចោទមួយរូបៗ នឹងមានរយៈពេល ៣០នាទី ដើម្បីលើកឡើងអំពីពាក្យស្នើសុំរបស់កូនក្តីរបស់ខ្លួន។ សហព្រះរាជអាជ្ញានឹងមានរយៈពេលសរុប ៦០នាទី ដើម្បីឆ្លើយតបទៅនឹងពាក្យស្នើសុំទាំងអស់។ បន្ទាប់មកសហមេធាវីការពារក្តីជនត្រូវចោទមួយរូបៗ នឹងទទួលបាន ១០នាទី បន្ថែមទៀត ដើម្បីឆ្លើយតបទៅនឹងសហព្រះរាជអាជ្ញា។

សាលសវនាការនៃ អ.វ.ត.ក មានកៅអីចំនួន៤៨២ សម្រាប់ទទួលអង្គទូត តំណាងសារព័ត៌មាន និងសាធារណជនទូទៅ។ គោលការណ៍នៃការបែងចែកកៅអីគឺ អ្នកដែលមកមុន បានកន្លែងអង្គុយមុន។ អង្គទូតនិងតំណាងសារព័ត៌មានដែលមានបំណងកក់កៅអីអង្គុយក្នុងសវនាការ សូមទាក់ទងមកផ្នែកកិច្ចការ

សាធារណៈនៃ អ.វ.ត.ក តាមរយៈសារអេឡិកត្រូនិក PAS@ECCC.GOV.KH យ៉ាងយឺតបំផុតត្រឹមថ្ងៃសុក្រ ទី២៨ ខែមករា ឆ្នាំ២០១១។

អ្នកចូលរួមគួរតែមកដល់ អ.វ.ត.ក យ៉ាងតិច ៤៥នាទី មុនពេលបើកសវនាការ ដើម្បីទុកពេលវេលាគ្រប់គ្រាន់សម្រាប់ឲ្យខាងសន្តិសុខចុះឈ្មោះនិងឆែកឆេរ។ ដើម្បីអាចចូលទៅក្នុងបរិវេណសាលសវនាការបាន អ្នកចូលរួមត្រូវតែបង្ហាញអត្តសញ្ញាណប័ណ្ណ (មានបិទរូបថត) និងឆ្លងកាត់ការត្រួតពិនិត្យសន្តិសុខ។

អ្នកចូលរួមត្រូវតែប្រកាន់អាកប្បកិរិយាសមរម្យនិងថ្លៃថ្នូរគ្រប់ពេលវេលា និងមានសម្លៀកបំពាក់ត្រឹមត្រូវ (មិនអនុញ្ញាតឲ្យស្លៀកខោខ្លី សម្លៀកបំពាក់នៅមាត់សមុទ្រ ឬសម្លៀកបំពាក់ស្តើងហួសហេតុ ឬពាក់ស្បែកជើងផ្ទាត់ ។ល។)។ អ្នកចូលរួមមិនត្រូវស្លៀកសម្លៀកបំពាក់ដែលមានពាក្យស្លោកដែលបង្ហាញការគាំទ្រឬមាក់ងាយដល់ក្រុមណាមួយឡើយក្នុងអំឡុងសវនាការ។ សូមកត់សម្គាល់ថា អ្នកដែលមានអាយុក្រោម ១៦ឆ្នាំ នឹងមិនត្រូវបានអនុញ្ញាតឲ្យចូលក្នុងសាលសវនាការឡើយ ហើយអ្នកដែលមានអាយុចាប់ពី ១៦-១៨ឆ្នាំត្រូវបានអនុញ្ញាតឲ្យចូលក្នុងសាលសវនាការតែក្នុងករណីមានមនុស្សចាស់មកជាមួយប៉ុណ្ណោះ។ មិនអនុញ្ញាតឲ្យយកទូរស័ព្ទដៃ កាបូបយួរឬស្ពាយ ចំណីអាហារឬភេសជ្ជៈ ចូលក្នុងសាលសវនាការឡើយ។

**ប័ណ្ណសម្រាប់តំណាងសារព័ត៌មាន និង សម្ភារៈផ្សេងៗទៀត**

តំណាងសារព័ត៌មានដែលមានបំណងចូលរួមស្តាប់សវនាការសូមដាក់ពាក្យសុំប័ណ្ណសារព័ត៌មានយ៉ាងយឺតបំផុតត្រឹមថ្ងៃសុក្រ ទី២៨ ខែមករា ឆ្នាំ២០១១។

តំណាងសារព័ត៌មានដែលមានប័ណ្ណព័ត៌មានដែលចេញដោយផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក ប៉ុន្តែហួសកំណត់ សូមបំពេញទម្រង់ពាក្យសុំសាជាថ្មី ដែលអាចទាញយកពី http://www.eccc.gov.kh/english/mediaRelations.aspx ដោយបំពេញលេខកាតចាស់ផង និងផ្ញើរមក PAS@ECCC.GOV.KH។

សម្រាប់អ្នកតំណាងសារព័ត៌មានដែលពុំធ្លាប់មានប័ណ្ណសារព័ត៌មានដែលចេញដោយផ្នែកកិច្ចការសាធារណៈនៃ អ.វ.ត.ក ត្រូវតែដាក់ពាក្យសុំដែលអាចទាញយកពី http://www.eccc.gov.kh/english/mediaRelations.aspx និងផ្ញើរមក PAS@ECCC.GOV.KH ដោយភ្ជាប់មកជាមួយនូវរូបថតនិងច្បាប់ចម្លងនៃលិខិតឆ្លងដែន។

សូមបញ្ជាក់ថា ពាក្យសុំប័ណ្ណសារព័ត៌មានត្រូវតែចុះហត្ថលេខាផ្ទាល់ដោយអ្នកស្នើសុំ។

អ.វ.ត.ក នឹងផ្តល់ការផ្សាយបន្តផ្ទាល់អំពីសវនាការ នៅក្នុងបន្ទប់លេខ C105 ដែលរៀបចំសម្រាប់អ្នកតំណាងសារព័ត៌មាន។

**តើធ្វើយ៉ាងណាដើម្បីទៅដល់ អ.វ.ត.ក ?**

អ.វ.ត.ក មានទីតាំងនៅខាងឆ្វេងដៃនៃផ្លូវជាតិលេខ៤ ក្នុងសង្កាត់ចោមចៅ ចម្ងាយ១៦គីឡូម៉ែត្រពីរាជធានីភ្នំពេញ។ តំណាងអ្នកសារព័ត៌មាននិងសាធារណជនសូមចូលតាមច្រកទ្វារសម្រាប់ភ្ញៀវដែលស្ថិតនៅទិសខាងកើត។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទង៖


**រាជ សម្បត្តិ**
ប្រធានផ្នែកកិច្ចការសាធារណៈ
ទូរស័ព្ទដៃ: +៨៥៥-១២ ៤៨៨ ១៥៦
ទូរសារ: +៨៥៥-២៣ ២១៩ ៨៤១
សារអេឡិចត្រូនិក: reach.sambath@eccc.gov.kh

**ឡាស អូលសិន**
មន្ត្រីទំនាក់ទំនងផ្នែកច្បាប់
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ 0២៣
សារអេឡិកត្រូនិក: olsenl@un.org

**ឌីម សុវណ្ណារុំ**
អ្នកនាំពាក្យសាលាក្តីខ្មែរក្រហម
ទូរស័ព្ទដៃ: +៨៥៥-១២ ៤៨៨ ០៩៤
ទូរសារ: +៨៥៥-២៣ ២១៩ ៨៤១
សារអេឡិចត្រូនិក: dim.sovannarom@eccc.gov.kh

**យូកូ ម៉ៃដា**
មន្ត្រីកិច្ចការសាធារណៈ
អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា (អ.វ.ត.ក.)
ទូរស័ព្ទចល័ត: +៨៥៥ (0) ១២ ៤៨៨ ៣១៩
សារអេឡិកត្រូនិក: maeday@un.org